# ពេលវេលា នៃ មហាជន

Le temps des masses

មហាជនខ្មែរ ជាការប្រមូលផ្ដុំ ដ៏ច្រើនលើសលប់ នៃជនខ្មែរ ជា **ពលករ គ្រប់មុខវិជ្ជាជីវៈ**[1] គ្រប់ឋានៈ ដែលមាននៅក្នុងសង្គម។ ការប្រមូលផ្ដុំនេះ គេច្រើន យកពាក្យ ប្រជាពលរដ្ឋ ឬ ប្រជាជាតិ មកប្រើរួមតែមួយ នៅក្នុងន័យ នៃវឌ្ឍកម្ម (progression) ទៅរក សេរីភាព និង **យុត្តិធម៌ប្រជាធិបតេយ្យ**[2]។

ក្នុងយាត្រា ទៅរក ភាពចំរើនលូតលាស់ នៃប្រជាជាតិ ត្រូវមាន ភាពស្រប (parallélisme) ឥតអាចបំបែកបាន ជាការចាំបាច់ នូវ អភិវឌ្ឍន៍ សេដ្ឋកិច្ច, សង្គមកិច្ច ជាមួយនឹង មហាយាត្រ នៃលទ្ធិប្រជាធិបតេយ្យ ដែលជា ការវិវឌ្ឍន៍ មាននៅក្នុង គ្រប់សង្គមជាតិ ក្នុងពិភពលោកនាបច្ចុប្បន្នកាលនេះ៖ សង្គមជាតិ លូតលាស់បាន តែងតែមាន លទ្ធិប្រជាធិបតេយ្យ ជារបបគ្រប់គ្រង ប្រជាជាតិ។ ដូច្នេះ បើសិន ជា **កម្លាំងអបរាជ័យ** ជា គំនិតប្រជាធិបតេយ្យ កើតចេញពី លទ្ធផល នៃជំនឿរួម ក្នុងពេលមាន **បដិវត្តន៍** មួយ កើតឡើងក្នុងសង្គម ដែលជា អ្នកដាស់តឿន ស្មារតី និង ចូលជ្រួតជ្រាប ក្នុងបេះដូង ពលរដ្ឋម្នាក់ៗ គឺ កម្លាំងអបរាជ័យ នេះ ពិតជា កត្តា ធ្វើឲមាន ការដុះដាល នៃលទ្ធិប្រជាធិបតេយ្យ តាម វឌ្ឍនភាព នៃបញ្ញា គ្រប់វិស័យ នៃមនុស្សជាតិ។ បើយោងតាម គំនិតខាងលើនេះ យើងអាច ពោលអះអាង បានថា «អត្ថិភាព នៃរដ្ឋាភិបាល ប្រជាធិបតេយ្យ សំរាប់ ដឹកនាំ មហាជន គឺជា លទ្ធផល សមហេតុផល នូវគ្រប់វឌ្ឍនភាព ដែលមាននៅក្នុង សម័យទំនើប។

ហេតុនេះឯង ត្រូវមាន ពេលវេលា នៃមហាជន សំរាប់ធ្វើការអប់រំ លើកដំកើង គំនិត លទ្ធិប្រជាធិបតេយ្យ។ **ការអប់រំមហាជន**[3] គឺ ជាការប្រគល់ សម្លេង ជូនដល់ ប្រជាពលរដ្ឋ ឲមានសិទ្ធិបញ្ចេញមតិ គ្រប់បែបយ៉ាង ជាសាធារណៈ ដើម្បី ធ្វើវិភាគ ឲបានច្បាស់លាស់ ថាអ្វីទៅ ដែលជា «ជំនឿ និង វិចារណញ្ញាណ»;«**គំនិតហួសវិស័យ**[4] និង គំនិតដែលអាចធ្វើបាន»;«**អភិសាមារចារ**[5]និង ច្បាប់»។

- មានជំនឿ គឺជាធម្មជាតិរបស់មនុស្ស តែបើពលរដ្ឋម្នាក់ៗ យកជំនឿខ្លួន មកពិចារណា រកហេតុផល ល្អ និង អាក្រក់ ឲដឹងច្បាស់ វាអាចនាំ ពង្រឹងបន្ថែម វិចារណញ្ញាណ ទៅលើអ្វីមួយ ដែលខ្លួន កំពុងជឿ ឬ បោះបង់វាចោល ជាបន្ទាន់ ព្រោះវា ជាអបិយជំនឿ។

[1] ពលករគ្រប់វិជ្ជាជីវៈ= Les classes laborieuses។
[2] យុត្តិធម៌ប្រជាធិបតេយ្យ= La justice démocratique។ ជាយុត្តិធម៌ ដោយ និង សំរាប់ប្រជាពលរដ្ឋ។
[3] ការអប់រំ មហាជន= Education des masses។
[4] គំនិតហួសវិស័យ=Utopie។
[5] អភិសាមារចារ=L’éthique។

- គំនិតហួសវិស័យ វាក៏អាចជា ពន្លក នៃគំនិតដែលអាចធ្វើបាន បើវាមាន មុខងារជាចម្លើយ នឹងសេចក្តី អស់សង្ឃឹម នៃពួក អ្នកទុទិដ្ឋិនិយម ដែលចេះតែសង្ស័យ ថាមិនអាច រំលំ របបផ្តាច់ការបាន ព្រោះ វាមាន មធ្យោបាយ គ្រប់បែបយ៉ាង សំរាប់ បង្ក្រាប ពួក អ្នកប្រឆាំងវា។

- គ្រប់ អភិសាមារចារ ដែលយកវា មកអនុវត្ត ដើម្បី ការរីកចំរើន នៃលទ្ធិប្រជាធិបតេយ្យ វានឹងប្តូររូប ជាច្បាប់ សំរាប់ការពារ ប្រជាពលរដ្ឋ។

វាក្មិន ឬ ក៏អាចជា បុគ្គលសាមញ្ញ ណាម្នាក់ អាចក្លាយជា សាស្ត្រាចារ្យ បើជននេះ មានវោហារកោសល្យ ប្រកបដោយ សិល្បៈឧបទេស ពន្យល់ ដល់អ្នកដទៃ អំពីគំនិត អ្វីមួយ បើនៅក្នុងឃ្លាពាក្យសកម្ម ទាំងឡាយ របស់គាត់ មានឧត្តមគំនិត ចេញពីបេះដូង ភាតរភាព ពិតប្រាកដ។ ការនេះជា សណ្ឋានមួយ នៃការអប់រំ មហាជន។

ការអប់រំ មហាជន គឺជា ការប្រគល់ សិទ្ធិ អោយ ប្រជាពលរដ្ឋ មានសេរីភាព អាចបញ្ចេញ មតិគ្រប់បែបយ៉ាង។ ក្នុងទង្វើនេះ បុគ្គលម្នាក់ៗ មានការទទួលខុសត្រូវ ដោយខ្លួនឯង ព្រោះខ្លួនជា ពលរដ្ឋ។ ការអប់រំ មហាជន មានមុខងារសំខាន់ ឲមនុស្សម្នាក់ៗ ចេញរួចពី **ភារៈ នៃព្យាបាលភាព**[6] ដែលខ្លួនឯង ជាអ្នកទទួលខុសត្រូវ។ ភារៈ នៃព្យាបាលភាព គឺជា ការខ្វះសម្ថភាពខ្លួនឯង ក្នុងការប្រើ **ពន្លឺបញ្ញា** (l’entendement) របស់ខ្លួនឯង ដោយគ្មានជំនួយពី អ្នកដទៃ។ សេចក្តីខ្ជិល, ការកំសាក វានាំឲមនុស្ស ភាគច្រើន ស្ថិតនៅក្នុង ភារៈ នៃព្យាបាលភាព ដោយរីករាយ អស់មួយជីវិត ព្រោះនាំគ្នាទុកវាជា **ភាសុកភាព** (confort) សំរាប់ខ្លួនៈ រស់រំពឹងជំនួយ វាងាយស្រួលជាង រស់ប្រកបមុខរបរ សំរាប់ចិញ្ចឹមជីវិត។ ទស្សនៈ បែបនេះ វាក្លាយទៅជា ធម្មជាតិ របស់ មនុស្ស ខ្ជិល នឹង កំសាក។ ធម្មជាតិនេះ វាពិបាក នាំមនុស្ស ឲចេញផុត ពី ភារៈ នៃព្យាបាលភាព នេះណាស់។ ហេតុនេះឯង ត្រូវចាំបាច់ ឲមាន ការអប់រំ មហាជន។

ការអប់រំ មហាជន ឈរនៅលើ សិទ្ធិ សេរីភាព និង ការទទួលខុសត្រូវ ដោយខ្លួនឯង របស់បុគ្គលម្នាក់ៗ ដែលជា ពលរដ្ឋ វាខុសគ្នាស្រឡះ ពីការអប់រំ មហាជន មាននៅក្នុង របបកុម្មុយនិស្ត ដែលជាការអប់រំ ឲប្រជាជន ជឿ និង រំពឹង ទៅលើតែ អង្គការ ដឹកនាំ បក្សកុម្មុយនិស្ត ដែលជា ការអប់រំ បង្ខំ មនុស្ស មិនឲប្រើ ពន្លឺបញ្ញា របស់ខ្លួន ដូចយ៉ាង អង្គការលើ ធ្វើអនុសាសថាៈ «កតព្វកិច្ច របស់ពលរដ្ឋ គឺត្រូវមានជំនឿ លើបក្សកុម្មុយនិស្ត ១០០% ដោយមិនត្រូវយកជំនឿនេះ មកគិតពិចារណា រកហេតុផលអ្វី នោះឡើយ»។

អ្វីដែលយើងបាន អធិប្បាយ ខាងលើនេះ នាំឲយើង អាចធ្វើសន្និដ្ឋានបានថា ពេលវេលានៃមហាជន នៅក្នុងស្រុកខ្មែរបច្ចុប្បន្ន គឺជា ពេលវេលា របស់ខ្មែរម្នាក់ៗ ធ្វើការ អប់រំខ្លួន ដោយខ្លួនឯង ដោយប្រើ សិទ្ធិសេរីភាពខ្លួន ជាពលរដ្ឋ ហ៊ានទទួលខុសត្រូវ លើវាសនាខ្លួន និង ប្រជាជាតិ។ ទោះបី មានបដិវត្តន៍មួយ អាចរំលំ របបផ្តាច់ការបាន តែបើ ខ្មែរម្នាក់ៗ គ្មានធ្វើកំណែទំរង់ ឲច្បាស់លាស់ នូវរបៀប ត្រិះរិះ របស់ខ្លួន នោះទេ ជ័យជំនះ របស់បដិវត្តន៍ ក្នុង ស្ថានភាព

[6] ភារៈ នៃព្យាបាលភាព=Etat de tutelle។

បែបនេះ គឺជាជ័យជំនះ របស់ការសងសឹក លើអ្វីមួយតែប៉ុណ្ណោះ ដូចយ៉ាងជា ជ័យជំនះ ពួកខ្មែរក្រហម នៅថ្ងៃទី ១៧ មេសា ឆ្នាំ ១៩៧៥ នោះឯង។

ប្រជាពលរដ្ឋខ្មែរ ត្រូវតែធ្វើ បដិវត្តន៍ តែជា បដិវត្តន៍ តាមផ្លូវបញ្ញា ធ្វើឡើង ដោយ ប្រជាជនមាន ការអប់រំ ខ្លួនឯង ដោយខ្លួនឯង ដើម្បី ឲស្គាល់ច្បាស់ ពីផលប្រយោជន៍ នៃបដិវត្តន៍និងគោលបំណងរបស់វា។ ខ្មែរម្នាក់ៗត្រូវមានសេចក្តីក្លាហាន ប្រើ ពន្លឺបញ្ញារបស់ខ្លួន ដើម្បី សេរីភាព នឹង ប្រយោជន៍ប្រជាជាតិ ដែលមានខ្លួនជា ពលរដ្ឋ ទទួលខុសត្រូវ។ នេះហើយជា បាវចនា នៃ ពន្លឺបញ្ញា។

ឧប សៅ សង្ហា

ថ្ងៃទី៨ តុលា ឆ្នាំ២០១៤